# កិច្ចព្រមព្រៀងបង្កើតក្រុមប្រឹក្សាឯករាជ្យនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

***ដោយ ម៉ៃឃឹល សាលីបា***

*ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត កែសម្រួលដោយ វ៉ាន់ថាន់ ពៅដារ៉ា*

កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតឲ្យមានអ្នកត្រួតពិនិត្យឯករាជ្យមួយ នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ តួនាទីថ្មីនេះនឹងជួយពង្រឹងការគ្រប់គ្រងធនធានមនុស្សរបស់ អ.វ.ត.ក និងផ្តល់ជាយន្តការមួយដើម្បីធានាថា រាល់បទចោទប្រកាន់ពីកំហុសឆ្គងទាំងឡាយត្រូវបានស៊ើបអង្កេត និងដោះស្រាយឲ្យបានត្រឹមត្រូវ ។ យោងតាមកិច្ចព្រមព្រៀងនេះ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានជ្រើសរើស អ៊ុត ឈន ដែលកំពុងបំពេញមុខងារជាអគ្គសនវិករនៃកម្ពុជាឲ្យមកធ្វើជាអ្នកត្រួតពិនិត្យឯករាជ្យទី១ ។ កិច្ចព្រមព្រៀងនេះត្រូវបានរៀបរៀងឡើងអស់រយៈពេលយ៉ាងយូរ និងត្រូវបានចាត់ទុកជាការវិវឌ្ឍជាវិជ្ជមានមួយពីសំណាក់ភាគីទាំងឡាយ ប្រទេសផ្តល់ជំនួយសំខាន់ៗ និងជាពិសេស គឺតុលាការខ្លួនឯងតែម្តង ។

## ប្រវត្តិកកើត និងសារសំខាន់របស់កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះកើតចេញពីដំណើរការចរចារជាច្រើនលើកច្រើនសាររវាងភាគីទាំងពីរ ។ ភាគីទាំងពីរបានជួបពិភាក្សាគ្នាចំនួន៣លើកមុននឹងសម្រេចចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ដោយលើកទី១ធ្វើឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៨ លើកទី២នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ និងលើកទី៣នៅថ្ងៃទី៦ដល់ទី៨ ខែមេសា ឆ្នាំ២០០៩ ។ ក្នុងពេលជួបចរចារភាគីទាំងពីរ បានប្រឹក្សា និងទទួលមតិយោបល់ពីសំណាក់មិត្តភក្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាអង្គការមួយដែលមានសមាសភាពឯកអគ្គរដ្ឋទូតនៃប្រទេសផ្តល់ជំនួយធំៗ ។

នេះគឺជាជំហានវិវត្តន៍ទៅមុខដ៏សំខាន់មួយសម្រាប់អង្គជំនុំជម្រះ ពីព្រោះកិច្ចព្រមព្រៀងបង្កើតឲ្យមានអ្នកត្រួតពិនិត្យឯករាជ្យមួយនេះនឹងជួយពង្រឹងដល់ការគ្រប់គ្រងធនធានមនុស្សនៅ អ.វ.ត.ក ។ ថ្មីៗនេះ

អង្គជំនុំជម្រះបានខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យដំណើរការនីតិវិធីរបស់តុលាការ បោះជំហានទៅមុខឲ្យបានលឿន ដើម្បីឲ្យស្របនឹងលក្ខខ័ណ្ឌតម្រូវនៃនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់ ។ យ៉ាងណាមិញ បញ្ហាដ៏សំខាន់មួយដែលអង្គជំនុំជម្រះ និងភាគីពាក់ព័ន្ធក្នុងដំណើរការនីតិវិធីបានជួបប្រទះនោះ គឺការខ្វះខាតនូវធនធាន ។ ដូចលោកសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ែ ពេទី បានលើកឡើងក្នុងសន្និសីតកាសែតកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៩ថា អង្គជំនុំជម្រះ“ពុំមានមូលនិធិ និងធនធានគ្រប់គ្រាន់ទេ” ។

សំខាន់ជាងនេះទៅទៀត តួនាទីថ្មីនេះហាក់បីដូចជាគាំទ្រនូវភាពត្រឹមត្រូវតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញចំពេលដែលមានការលេចឮរឿងពុករលួយ និងការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ឧទាហរណ៍ យោងតាមលិបិក្រមនៃសញ្ញាណពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ ប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសមួយក្នុងចំណោមប្រទេសពុករលួយបំផុតនៅក្នុងពិភពលោក ដែលជាប់ចំណាត់ថ្នាក់ខ្ពស់គឺទី១៦៦ក្នុងចំណោម១៨០ប្រទេស ។ (លិបិក្រមនេះបានកំណត់អំពើពុករលួយថា ជាការរំលោភបំពានរបស់មន្ត្រីសាធារណៈដើម្បីប្រយោជន៍ឯកជនផ្ទាល់ខ្លួន ហើយស្ទង់ដឹងពីកម្រិតពុករលួយនេះកើតមានក្នុងចំណោមមន្ត្រីសាធារណៈ និងអ្នកនយោបាយក្នុងប្រទេសទៀតផង) ។

ច្បាស់ជាងនេះទៀត មានការចោទប្រកាន់ជាបន្តបន្ទាប់ពីការជ្រៀតជ្រែកផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទិននឹងសេចក្តីសម្រេចថា តើគួរតែកាត់ទោសសមាជិករបស់របបខ្មែរក្រហមបន្ថែមទៀតដែរឬទេនៅអង្គជំនុំជម្រះវិសាមញ្ញ ។ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិបានខ្វែងគំនិតគ្នាលើបញ្ហានេះ ក៏ប៉ុន្តែមានរបាយការណ៍មួយបាននិយាយថា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់ប្រធានាធិបតី នីកូឡា សាកូហ្ស៊ី ថា តុលាការនេះកាត់ទោសតែមេដឹកនាំខ្មែរក្រហម ៥នាក់ដែលត្រូវបានទទួលការចោទប្រកាន់នោះបានហើយ ។ សំដីបែបនេះ បានធ្វើឲ្យអង្គការឃ្លាំមើលសិទ្ធិមនុស្សចោទប្រកាន់នាយករដ្ឋមន្ត្រីពីបទព្យាយាមប្រើប្រាស់អំណាចរបស់ខ្លួនមកលើមន្ត្រីកម្ពុជា ដែលបំរើការងារនៅតុលាការ ដើម្បីជ្រៀតជ្រែកក្នុងកិច្ចការរបស់តុលាការដែលបណ្តាលឲ្យមានបញ្ហាចោទដល់ឯករាជ្យភាពរបស់តុលាការ ។ សហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ែ ពេទី បានមានយោបល់ថា នេះគឺជា“ការរំខាន” ដែលមន្ត្រីនានាទទួលបានការតែងតាំង និងភាគីដទៃទៀតគិតថា គេអាចប្រាប់តុលាការឲ្យធ្វើអ្វីដែលតុលាការគួរតែធ្វើបានហើយ ។

## សេចក្តីសន្និដ្ឋាននៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះ នឹងពង្រឹងការគ្រប់គ្រងធនធានមនុស្សរបស់ អ.វ.ត.ក និងជួយធានាថាតុលាការដំណើរការទៅមុខស្របតាមបទដ្ឋានអន្តរជាតិស្តីពីនីតិវិធីត្រឹមត្រូវតាមផ្លូវច្បាប់ ។ កិច្ចព្រមព្រៀងបានគូសបញ្ជាក់ថា អ្នកត្រួតពិនិត្យត្រូវតែជាបុគ្គលដែលមានសេចក្តីថ្លៃថ្នូរ និងមានកេរ្តិ៍ឈ្មោះល្អ ។ ដើម្បីធានាពីឯករាជ្យភាព អ្នកត្រួតពិនិត្យត្រូវតែមិនមែនជាបុគ្គលិករបស់ អ.វ.ត.ក ឬអង្គការសហប្រជាជាតិ ឬជាអ្នកនយោបាយដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាឡើយ ។ ជាវិបាក រាល់ការចំណាយលើការបង្កើត និងរក្សាតួនាទីនេះនឹងត្រូវទទួលខុសត្រូវរួមគ្នាដោយស្មើភាពរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។

នៅពេលដែលបុគ្គលិក ឬបុគ្គលណាម្នាក់ដែលជាប់ពាក់ព័ន្ធនឹងការសង្ស័យរបស់តុលាការថា មានកំហុសឆ្គងណាមួយនោះ បុគ្គលនោះនឹងរាយការណ៍ជូនអ្នកត្រួតពិនិត្យឯករាជ្យអំពីកំហុសឆ្គងនោះ ។ នៅពេលដែលអ្នកត្រួតពិនិត្យឯករាជ្យទទួលបានពាក្យបណ្តឹង អ្នកត្រួតពិនិត្យឯករាជ្យនឹងធ្វើការស៊ើបអង្កេតលើការប្រព្រឹត្តឆ្គងនោះ ។ ប្រសិនបើការស៊ើបអង្កេតរកឃើញកំហុសហើយ នោះអ្នកត្រួតពិនិត្យឯករាជ្យនឹងរាយការណ៍ជូនឧបនាយករដ្ឋមន្ត្រីកម្ពុជា និងជំនួយការអគ្គលេខាធិការទទួលបន្ទុកកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ ដែលអ្នកទាំងពីរនឹងលៃលកដោះស្រាយបញ្ហាតាមរយៈការពិគ្រោះយោបល់ឲ្យបានសមស្រប ។ ពេញមួយដំណើរការនេះ អ្នកពិគ្រោះយោបល់ឯករាជ្យនឹងរក្សានូវការសម្ងាត់ឲ្យបានខ្ពស់បំផុតដោយមិនអនុញ្ញាតឲ្យបុគ្គលិក ណាម្នាក់របស់ អ.វ.ត.ក ដឹងទេ ហើយបុគ្គលទាំងអស់ដែលរាយការណ៍ពីការប្រព្រឹត្តកំហុសឆ្គងរបស់បុគ្គលណាម្នាក់ផ្សេងទៀតនឹងត្រូវបានការពារពីការប៉ុនប៉ងព្យាបាទផ្សេងៗ ។

## ប្រតិកម្មវិជ្ជមានចំពោះកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះត្រូវបានគិតគូរអស់រយៈពេលយ៉ាងយូរ និងបានទទួលបាននូវការគាំទ្រយ៉ាងពេញទំហឹងពីអ.វ.ត.ក ក៏ដូចជាមិត្តភក្តិរបស់ អ.វ.ត.ក ដែរ ។

ឯកអគ្គរាជទូតជប៉ុន និងការធារីទូតរបស់បារាំងដែលកំពុងបំរើការជាសហប្រធាននៃមិត្តភក្តិ អ.វ.ត.ក បានចេញសេចក្តីថ្លែងការជាផ្លូវការមួយកាលពីថ្ងៃទី១២ ខែសីហា ដើម្បីបង្ហាញពីការគាំទ្រយ៉ាងពេញទំហឹងរបស់ខ្លួន ។ លោកទាំងពីរបានថ្លែងថា កិច្ចព្រមព្រៀងនេះអាចផ្តល់ជាយន្តការដ៏មានប្រសិទ្ធិភាព និងជឿទុកចិត្តបាន ដែលចាំបាច់ដើម្បីបន្តពង្រឹងកិច្ចការរដ្ឋបាលរបស់តុលាការ ។ ខ្លួនក៏បានស្វាគមន៍ចំពោះការតែងតាំងលោកអគ្គសវនករនៃកម្ពុជា ជាអ្នកពិគ្រោះយោបល់ឯករាជ្យថែមទៀតផង ។ ទោះបីជាមិត្តភក្តិតុលាការមិនមែនជាភាគីនៃកិច្ចព្រមព្រៀងក៏ដោយ វានៅតែជាផ្នែកមួយដែលជួយដល់ដំណើរការចចារទាំងមូលឲ្យឈានដល់កិច្ចព្រមព្រៀងនៅទីបញ្ចប់ តាមរយៈការពិគ្រោះយោបល់ដ៏លម្អិតពីសំណាក់មិត្តភក្តិ អ.វ.ត.ក ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាត់ទុកកិច្ចព្រមព្រៀងនេះថាជាការវិវត្តន៍វិជ្ជមានមួយ ។ ការិយាល័យកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះបានរៀបចំសន្និសីទកាសែតមួយកាលពីថ្ងៃទី១២ ខែសីហា ដើម្បីសម្តែងការគាំទ្រយ៉ាងពេញទំហឹងរបស់ខ្លួនចំពោះកិច្ចព្រមព្រៀងនេះ ។ ការិយាល័យកិច្ចការសាធារណៈបានកត់សម្គាល់ថា ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះក៏ដោយ ក៏កិច្ចព្រមព្រៀងនេះនៅតែផ្តល់ប្រយោជន៍ដ៏សំខាន់ពីព្រោះថា តួនាទីថ្មីនេះនឹងជួយកែលំអរកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និងជួយដោះស្រាយបញ្ហាចោទពីបទពុករលួយ ។ ការិយាល័យកិច្ចការសាធារណៈបានសង្កត់ធ្ងន់ថា អង្គជំនុំជម្រះវិសាមញ្ញកំពុងរង់ចាំស្វាគមន៍អ្នកពិគ្រោះយោបល់ឯករាជ្យ ហើយនិងធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹងជាមួយនឹងអ្នកពិគ្រោះយោបល់នោះខណៈពេលដែលគាត់ចាប់ផ្តើមអនុវត្តការងាររបស់ខ្លួន ។

កិច្ចព្រមព្រៀងដែលត្រូវបានទន្ទឹងរង់ចាំជាយូរមកហើយនេះ ទទួលបាននូវភាពជាវិជ្ជមានពីភាគីពាក់ព័ន្ធទាំងអស់ ។ កិច្ចព្រមព្រៀងនេះនឹងពង្រឹងការគ្រប់គ្រងធនធានមនុស្សនៅ អ.វ.ត.ក និងលើកកម្ពស់ភាពត្រឹមត្រូវតាមផ្លូវច្បាប់របស់តុលាការចំពេលដែលមានរឿងពុករលួយ និងការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយដោយរាជរដ្ឋាភិបាលកម្ពុជាកើតមានឡើង ។ នេះគឺជាការអភិវឌ្ឍប្រកបដោយផ្លែផ្កាសម្រាប់តុលាការ និងការបោះជំហានទៅមុខយ៉ាងលឿនមួយដែលនឹងធានាថា យុត្តិធម៌នឹងត្រូវសម្រេចបាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយ៉ាងពិតប្រាកដ ។